WOORIE GARMENTS
CAMBODIA


**វូ៉រី ហ្គាមេន ខូអិលធីឌី**

**WOORIE GARMENTS CO., LTD.**

ដីឡូត៍លេខ 605, ភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : 089 363 666 / 067 363 666


**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ០០៦

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន វូ៉រី ហ្គាមេន ខូអិលធីឌី
# និង
# តំណាងប្រតិភូបុគ្គលិក និងសហជីពចលនាកម្មករប្រចាំរោងចក្រ វូ៉រី ហ្គាមេន
# ស្ដីអំពីការព្យួរការងារ

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង៩និង៣០នាទី នៅក្នុងរោងចក្រ វូ៉រី ហ្គាមេន ខូអិលធីឌី មានកិច្ចប្រជុំមួយ រវាង តំណាងក្រុមហ៊ុន និង តំណាងកម្មករ សហជីពចលនាកម្មករ ប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់បងប្អូនកម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរោងចក្រថា ពេលនេះរោងចក្រមិនមានការបញ្ជាទិញ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូល ដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរការងារ របស់បងប្អូនបុគ្គលិកកម្មករកម្មការិនីចំនួន **ពីរខែ** គឺចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ទៅដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ ក្រុមហ៊ុននឹងផ្ដល់ប្រាក់ឧបត្ថម្ភ ចំនួន **៣០ដុល្លារ** ក្នុង១ខែ ដោយយោងតាមសេចក្ដីប្រកាសលេខ ០៤៥ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សម្រាប់កម្មករនិយោជិតម្នាក់ៗ។

ក្នុងអំឡុងពេល២ខែនេះ រោងចក្រ នឹងទុកកម្មករនិយោជិតមួយចំនួន ទៅតាមការចាត់ចែងរបស់ក្រុមហ៊ុន អោយធ្វើការធម្មតា ដើម្បីសំរួលការងារមួយចំនួនរបស់រោងចក្រ ។

អង្គប្រជុំបានចប់វេលាម៉ោង១១និង២០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ថ្ងៃច័ន្ទ ៦កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២០

**តំណាងកម្មករ និង តំណាងសហជីព** | **នាយកក្រុមហ៊ុន**

១. សុខ វណ្ណា ២. ទុំ ធារ៉ា ៣. សាំង ពិសី

ព្រះរាជាណាចក្រកម្ពុជា វូ៉រី ហ្គាមេន WOORIE GARMENTS Co., Ltd. ចុះបញ្ជីពាណិជ្ជកម្មរាជធានីភ្នំពេញ

**រ៉ាយ សុខឃីម**